**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

លេខ: ២៩៨៩ មស.ប្រក

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៦១ អនក្រ.តត ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- បានឃើញប្រកាសលេខ ២៨៤៨ មស.ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងតាមសំណើរបស់ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

**ប្រការ១.-**

ត្រូវបានតែងតាំងសមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ "ល.គ.ក.រ" ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម | **គង់ សុភី** | ប្រធាន |
| ២-ឯកឧត្តម | **ឆាយ នគ្រាឧត្តម** | អនុប្រធានអចិន្ត្រៃយ៍ |



អាសយដ្ឋាន: (កែងផ្លូវលេខ២០០៤) ភូមិពោធិ៍ចំប៉ា សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ ភ្នំពេញ ទូរស័ព្ទ/ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

| | | |
|---|---|---|
| ៣-លោកជំទាវ | នាង លីណា | អនុប្រធាន |
| ៤-ឯកឧត្តម | ស៊ឹម សារឿន | អនុប្រធាន |
| ៥-លោកស្រី | ណាយ គឹមសុទ្ធី | អនុប្រធាន |
| ៦-លោក | សយ រាសី | មន្ត្រីទទួលបន្ទុកផ្នែកសេវាសាធារណៈ |
| ៧-លោក | ធន់ ម៉ីនឡឿន | មន្ត្រីទទួលបន្ទុកផ្នែកគ្រប់គ្រងធនធានមនុស្សនិងអភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន |
| ៨-លោក | ប្រាក់ ម៉ុច | មន្ត្រីទទួលបន្ទុកផ្នែកបៀវត្សនិងលាភការ |
| ៩-លោក | ប្រាក់ ប្រានីដ្ឋា | មន្ត្រីទទួលបន្ទុកផ្នែកតាមដានត្រួតពិនិត្យនិងវាយតម្លៃ |
| ១០-លោក | ឡុងសារឿន | មន្ត្រីទទួលបន្ទុកផ្នែកអភិវឌ្ឍព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធាណៈ |
| ១១-លោកស្រី | ថ្លែក វីណែត | មន្ត្រីទទួលបន្ទុកការងារទំនាក់ទំនងសាធារណៈ |
| ១២-លោក | លន គឹមហេង | មន្ត្រីទទួលបន្ទុកផ្នែកគាំទ្រប្រតិបត្តិការ |
| ១៣-លោក | ឡៀវ សត្យា | មន្ត្រីទទួលបន្ទុកការងាររដ្ឋបាល |
| ១៤-លោក | គាន់ ទេពណាង | មន្ត្រីទទួលបន្ទុកការងារបុគ្គលិក |
| ១៥-លោកស្រី | ម៉ៅ ចិន្តា | មន្ត្រីទទួលបន្ទុកការងារហិរញ្ញវត្ថុ ។ |

**ប្រការ ២.-**

សមាសភាពលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានរាយនាមក្នុងប្រការ១ ខាងលើ ត្រូវបំពេញភារកិច្ចអនុលោមខ្លឹមសារនៃប្រកាសលេខ ២៨៤៨ មស.ប្រក ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គាធិការនៃអគ្គាធិការដ្ឋានមុខងារសាធារណៈ នាយកសាលាភូមិន្ទរដ្ឋបាល គ្រប់ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែ សីហា ឆ្នាំ ២០១៤

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ